# របាយការណ៍
# ស្តីពី
# លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ ធ្នូ ឆ្នាំ២០១០
# និង ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ មករា ឆ្នាំ២០១១

(០១/១២/២០១០-៣១/១២/២០១០)

ខែធ្នូឆ្នាំ២០១០ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានយកចិត្តទុកដាក់អនុវត្តតាមទិសដៅពហុវិស័យ ដែលបានដាក់ចេញកាលពីខែវិច្ឆិកា សំដៅរួមចំណែករក្សាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ស្របតាមកម្មវិធីនយោបាយជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤ នៃរដ្ឋសភា ។ ជាក់ស្តែង សកម្មភាពនិងលទ្ធផលការងារដែលអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនខិតខំអនុវត្តសម្រេចបានក្នុងខែធ្នូនេះ មានដូចខាងក្រោម ៖

## I. សភាពការណ៍គ្រឿងញៀន

### ១. សភាពការណ៍គ្រឿងញៀនអន្តរជាតិ

តាមរយៈកិច្ចប្រជុំស្តីពី ការទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី៣០ខែវិច្ឆិកា រហូតដល់ថ្ងៃទី០៣ខែធ្នូឆ្នាំ២០១០ កម្លាំងប៉ូលីសសហព័ន្ធអូស្ត្រាលីបានបង្ហាញឱ្យឃើញថា ការបង្វែរសារធាតុគីមីផ្សំគ្រឿងញៀនមានការប្រែប្រួលគួរឱ្យកត់សំគាល់ ។ គេបានរកឃើញ ពួកឧក្រិដ្ឋជនគ្រឿងញៀនបានប្រើប្រាស់គ្រប់រូបភាព ដើម្បីគេចពីកម្លាំងមានសមត្ថកិច្ច ដូចជា ការផ្លាស់ប្តូរទ្រង់ទ្រាយនៃការផលិតពីរូបភាពធំទៅជារូបភាពតូចៗ ឬ ពីក្នុងទីតាំងច្បាស់លាស់ទៅជាការផលិតចល័ត ។

ដើម្បីទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំគ្រឿងញៀនឱ្យកាន់តែមានប្រសិទ្ធភាព អង្គប្រជុំបានឯកភាពទៅលើការពង្រឹងច្បាប់ ការអនុវត្តន៍ច្បាប់ ពិសេស បំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីវិស័យឯកជន ទាំងលើការគ្រប់គ្រងសារធាតុគីមី ក៏ដូចជាការគ្រប់គ្រងឱសថដែលមានសារជាតិញៀន ដោយកំណត់ថា យន្តការរួមរវាងរដ្ឋ និង ឯកជន គឺជាចំណុចស្នូលក្នុងការតាមដាននិងត្រួតពិនិត្យការផលិត ចរាចរ ប្រើប្រាស់សារធាតុគីមី និងឱសថដែលមានសារធាតុគីមីផ្សំគ្រឿងញៀន ។

### ២. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

ក្នុងខែធ្នូនេះ តាមរយៈលទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា ខេត្តស្ទឹងត្រែង និងខេត្តព្រះវិហារ នៅ

តែជាច្រកដ៏សំខាន់ ក្នុងការនាំគ្រឿងញៀនប្រភេទ **មេតំហ្វេតាមីនគ្រាប់** និង **មេតំហ្វេតាមីនទឹកកក**(ICE) ចូលមកកម្ពុជា ដោយពួកឈ្មួញគ្រឿងញៀនប្រទេសជិតខាងដែលនៅភាគខាងជើងនៃប្រទេសកម្ពុជា ។ គ្រឿងញៀនទាំងនោះ មួយចំនួនត្រូវបានគេធ្វើការផ្គត់ផ្គង់សំរាប់ការប្រើប្រាស់នៅក្នុងស្រុក និងមួយចំនួនត្រូវបាននាំចេញទៅក្រៅប្រទេស ជាក់ស្តែង នៅក្នុងខែនេះ ពួកឈ្មួញបាននាំយកមេតំហ្វេតាមីនទឹកកក ក្នុងចំនួនមួយគួរកត់សំគាល់ទៅកាន់ប្រទេសម៉ាឡេស៊ី តាមច្រកព្រលានយន្តហោះអន្តរជាតិភ្នំពេញ ប៉ុន្តែត្រូវសមត្ថកិច្ចធ្វើការបង្ក្រាបទាន់ពេលវេលា ។

ដោយឡែក ការនាំចូលឱសថដែលមានផ្ទុកសារធាតុ ផ្សឺដូ-អេហ្វេឌ្រីន (Pseudo-Ephedrine) ក៏ត្រូវបានពួកឈ្មួញនាំចូលមកកម្ពុជាម្តងទៀត បន្ទាប់ពីមានការនាំចូលដោយខុសច្បាប់កាលពីថ្ងៃទី២២ខែសីហាឆ្នាំ២០១០កន្លងមក ។ ការនាំចូលលើកនេះ ត្រូវបានពួកឈ្មួញបញ្ជូនពីប្រទេសកូរ៉េខាងត្បូង ឆ្លងកាត់ប្រទេសវៀតណាម ឆ្ពោះមកកំពង់ផែអន្តរជាតិក្រុងព្រះសីហនុ(ខេត្តព្រះសីហនុ) ហើយដឹកមករាជធានីភ្នំពេញដោយស្តុកទុកនៅផែស្ងួត **តេងឡាយ** រួចទើបលបលួចបំបែកតាមគោលដៅចំនួនពីរកន្លែងស្ថិតនៅក្នុងរាជធានីភ្នំពេញ ។ ទន្ទឹមនេះ ក៏មានមួយករណី បាននាំសារធាតុគីមីផ្សំ EPHE-DRINE ដោយដាក់បង្កប់ក្នុងកញ្ចប់បញ្ញើ ហើយផ្ញើតាមក្រុមហ៊ុនសេវាកម្មដឹកជញ្ជូនរបស់ Fedex ពីប្រទេសឥណ្ឌាចូលមកកម្ពុជា ។ ករណីទាំងពីរនេះ ត្រូវបានសមត្ថកិច្ចធ្វើការបង្ក្រាបទាន់ពេលវេលា ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *ការងារដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានយកចិត្តទុកដាក់លើកកំពស់វិធានការពហុវិស័យក្នុងការត្រួតពិនិត្យគ្រឿងញៀន ជាអាទិ៍ :

-ការចូលរួមក្នុងទិវាពិភពលោកប្រយុទ្ធនឹងជម្ងឺអេដស៍ ថ្ងៃទី០១ខែធ្នូឆ្នាំ២០១០ នៅសាលសន្និសីទចតុមុខ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោកជំទាវបណ្ឌិត **ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា ។

-ការជំរុញក្រសួងយុត្តិធម៌ឱ្យបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលទើបកែសម្រួលថ្មី ទៅទីស្តីការគណៈរដ្ឋមន្ត្រី ។

-ការណែនាំឱ្យសហការជាមួយក្រសួងផែនការ ដើម្បីពិនិត្យពិភាក្សាលើសូចនាករសំខាន់ៗ សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តន៍ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ។

-ការណែនាំឱ្យរៀបចំយន្តការបង្កើត "សាលារៀនបៃតងគ្មានគ្រឿងញៀន" ។

### *១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសហការសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ធ្វើការផ្សព្វផ្សាយអប់រំលើកកំពស់ការយល់ដឹងជាសាធារណៈអំពីច្បាប់និងគ្រោះថ្នាក់នៃគ្រឿងញៀន តាមរយៈសកម្មភាព ដូចជា :

-ការផ្តល់បទសម្ភាសន៍តាមកម្មវិធីប្រចាំខែរបស់កម្មវិធី **CTN Internet** ។

-ការធ្វើបទបង្ហាញស្តីពីផលប៉ះពាល់នៃគ្រឿងញៀន ដល់និស្សិតវិទ្យាស្ថាន ប៊ែលធី សាខាស្ទឹងមានជ័យ ថ្ងៃទី ១៦

ខែ ធ្នូ ឆ្នាំ ២០១០ ។

-ការគាំទ្រ និងបំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល ក្រុមហ៊ុនសេវាកម្មដឹកជញ្ជូនអ្នកដំណើរ ជាដើម ។

-ការបន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យលើទម្រង់ ខ្លឹមសារ រូបភាព នៃSticker ផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន ។

**សកម្មភាពទាំងអស់ខាងលើ** រួមបញ្ចូលទាំងការងារផ្សព្វផ្សាយអប់រំប្រចាំខែរបស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្តនានាផង គឺមានមហាជន/ប្រជាជន ចូលរួមសរុបចំនួន **២៦.១៤១** នាក់ ។

ដោយឡែក អង្គការមុស្លីមអេដស៍កម្ពុជា បន្ទាប់ពីបានអនុវត្តគម្រោងសាកល្បងស្តីពី ***"ការលើកកំពស់បរិស្ថានសាលារៀន ឱ្យកាន់តែប្រសើរឡើងតាមរយៈការផ្តល់ការអប់រំគ្មានការប្រើប្រាស់គ្រឿងញៀននៅតាមសាលារៀន និងការផ្តល់សេវាកម្មគាំទ្រផ្អែកលើមូលដ្ឋានសហគមន៍កម្ពុជា"*** អស់រយៈពេល៦ខែកន្លងមក បានរៀបចំសិក្ខាសាលា នាថ្ងៃទី២៣ខែធ្នូឆ្នាំ២០១០ នៅសណ្ឋាគារឡាផារ៉េងដា(ភ្នំពេញ) ក្នុងគោលបំណងចែករំលែកបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៏គម្រោង, ការបង្ហាញពីឧបសគ្គក្នុងអំឡុងពេលនៃការអនុវត្តន៏គម្រោងនិងភាពជំនះលើឧបសគ្គទាំងនោះ, និងការពិភាក្សាលើបទពិសោធន៍ដែលទទួលបានពីការអនុវត្តន៏គម្រោង ដើម្បីយកទៅអនុវត្តបន្តនៅខេត្តបន្ទាយមានជ័យ ។

ជាមួយបណ្តាប្រទេសក្នុងតំបន់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់មន្ត្រីជំនាញទៅចូលរួមកិច្ចប្រជុំដៃគូអនុវត្តកម្មវិធីIOGT-NTO MOVEMENT នៅទីក្រុងឆាអាម ប្រទេសថៃ(២៤-២៥/១១/២០១០)ដែលកម្មវិធីនេះគឺជាផ្នែកសកម្មភាពមួយរបស់អង្គការSIDA ប្រទេសស៊ុយអែត ដែលផ្តោតលើបណ្តាញសកម្មភាពនិងព័ត៌មានស្តីពីការត្រួតពិនិត្យការប្រើបំពានគ្រឿងញៀនក្នុងតំបន់ ។ នៅកម្ពុជា កម្មវិធីនេះបានជ្រើសរើសយក ***សមាគមយុវជនខ្មែរ, អង្គការពន្លឺកុមារកម្ពុជា, មណ្ឌលព័ត៌មានស្ត្រីកម្ពុជា*** និង ***មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព*** ក្នុងការធ្វើសកម្មភាពផ្សព្វផ្សាយអប់រំបង្ការការប្រើបំពានគ្រឿងញៀន និងសកម្មភាពបង្ការនិងកាត់បន្ថយការប្រើប្រាស់គ្រឿងស្រវឹងនៅកម្ពុជា ។

### ***២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន***

ខែធ្នូឆ្នាំ២០១០ បង្ក្រាបបទល្មើសបាន **៣០** ករណី (មានកំណត់ចំណាំពីរនៅទំព័រទី១១) ឃាត់ខ្លួនជនល្មើស**៤៦**នាក់ (ប្រុស**៣៤**នាក់ ស្រី**១២**នាក់) ក្នុងនោះ ជនជាតិខ្មែរ**៤១**នាក់ (ប្រុស**៣២**នាក់ ស្រី**៩**នាក់), វៀតណាម**៤**នាក់(ប្រុស**១**នាក់ ស្រី**៣**នាក់), ឡាវ**១**នាក់ (ប្រុស) ។ **វត្ថុតាងចាប់យក រួមមាន :**

-មេតំហ្វេតាមីនគ្រាប់ស្លាកសញ្ញា WY 9.039 គ្រាប់

-មេតំហ្វេតាមីនICE 2 Kg 737,28 gs និង1កញ្ចប់

-ហេរ៉ូអ៊ីន 0,83 Kgs

-ដំណាំកញ្ឆា 33 ដើម

-ម្សៅពណ៌ ស 31 ដុំ = 12,4 Kgs

-ម្សៅពណ៌ក្រហម 3 ថង់

-ឱសថមានផ្ទុកសារធាតុ ផ្សីដូ-អេហ្វេឌ្រីន ចំនួន៧៤កេស្ត ស្មើនឹង ១៣.២៩៥ កំប៉ុង ស្មើនឹង ៦.៦៤៧.000 គ្រាប់

និងវត្ថុតាងផ្សេងទៀតរួមមាន ពុម្ព2 ឆ្នាំងសម្ងួត 1 កាំភ្លើងវែង 3ដើម កាំភ្លើងខ្លី 1ដើម រថយន្ត 5គ្រឿង ម៉ូតូ 2 គ្រឿង និងឧបករណ៍ប្រើប្រាស់មួយចំនួន ។

ដោយឡែក **សារធាតុគីមីផ្សំ** ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលដោយក្រសួងឧស្សាហកម្មរ៉ែនិងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងខែធ្នូ ឆ្នាំ២០១០ នេះ សរុបមានចំនួន 3.059.642 Kg និង 94 L ។

### ៣-ការព្យាបាល និងស្តារនីតិសម្បទា និងការកាត់បន្ថយគ្រោះថ្នាក់នានា

#### -ការព្យាបាល និង ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន

តបតាមការស្នើសុំរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រាជរដ្ឋាភិបាលបានយល់ព្រមប្រគល់ភារកិច្ចឱ្យក្រសួងសង្គមកិច្ចអតីតយុទ្ធជននិងយុវនីតិសម្បទា ទទួលខុសត្រូវក្នុងការរៀបចំដំណើរការនិងគ្រប់គ្រងមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតសម្បទាអ្នកញៀនគ្រឿងញៀន ។

ទន្ទឹមនេះ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក៏បានប្រគល់គ្រែដែក ចំនួន **៣៥៨** គ្រែ ដល់មណ្ឌលបណ្តោះអាសន្នអប់រំ បន្សាប ព្យាបាលអ្នកញៀនគ្រឿងញៀន**ពិភពនៃក្តីសង្ឃឹម**ខេត្តបាត់ដំបង ចំនួន ១៥០ គ្រែ, មណ្ឌលរបស់**កងរាជអាវុធហត្ថខេត្តបាត់ដំបង** ចំនួន ១៥០ គ្រែ, មណ្ឌលរបស់**នគរបាលខេត្តសៀមរាប** ចំនួន ៤០ គ្រែ, និង មណ្ឌលរបស់**កងរាជអាវុធហត្ថខេត្តព្រះសីហនុ** ចំនួន ១៨ គ្រែ និងសម្ភារៈប្រើប្រាស់ចាំបាច់មួយចំនួនទៀត ។

ដោយឡែក ដើម្បីចូលរួមចំណែកអនុវត្តយន្តការនៃការងារព្យាបាលជាមួយបណ្តាប្រទេសនៅក្នុងតំបន់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីមជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀនដោយបង្ខំនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក កាលពីថ្ងៃទី១៤-១៦ខែធ្នូឆ្នាំ២០១០ នៅទីក្រុងបាងកក ប្រទេសថៃ ។ កិច្ចប្រជុំនេះ មានគោលបំណងពិនិត្យមើលពីទិដ្ឋភាពច្បាប់ គោលនយោបាយ និងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិនានា ក្នុងការឆ្លើយតបចំពោះអ្នកប្រើ និងអ្នកញៀនគ្រឿងញៀន រួមទាំងមជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀនដោយបង្ខំ ដើម្បីកាត់បន្ថយបាននូវអត្រានៃការលាប់ឡើងវិញ, ការទប់ស្កាត់បានការឆ្លងរាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ និងជម្ងឺឆ្លងផ្សេងៗ, ការរក្សាបាននូវនិរន្តរភាព និងប្រសិទ្ធភាពនៃការព្យាបាល និងអាចកាត់បន្ថយបាននូវការចំណាយខ្ពស់ក្នុងការព្យាបាល ។

#### -ការកាត់បន្ថយគ្រោះថ្នាក់នានា

ដើម្បីចូលរួមចំណែកក្នុងការងារបង្ការទប់ស្កាត់គ្រោះថ្នាក់នានា ដែលបណ្តាលមកពីការប្រើបំពានគ្រឿងញៀនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន :

- បានអនុញ្ញាតឱ្យអង្គការមិត្តសម្លាញ់អនុវត្តកម្មវិធីប្តូរម្ជុល/ស៊ីរ៉ាំងបន្ត រយៈពេល១ឆ្នាំ(០១មករា-៣១ធ្នូ២០១១) ដោយរក្សាការផ្តល់បណ្ណ័សម្គាល់ខ្លួនសម្រាប់បុគ្គលិកបម្រើសេវា ដោយអគ្គលេខាធិការដ្ឋាន អជបគញ តាមគោលនយោបាយ និង គោលការណ៍ណែនាំ ដែលកំពុងដាក់ឱ្យអនុវត្តបច្ចុប្បន្ន ។ ជាមួយនេះដែរ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុញ្ញាតជាគោលការណ៍ឱ្យមណ្ឌលសំចតសាខាមានជ័យរបស់អង្គការ Khana អនុវត្តនូវកម្មវិធីម្ជុល/ស៊ីរ៉ាំង នៅរាជធានីភ្នំពេញផងដែរ ។
- បានចូលរួមក្នុងសិក្ខាសាលា ស្តីពីការពង្រឹងសមត្ថភាពមន្ត្រីក្រុមការងារប្រយុទ្ធនឹងជម្ងឺអេដស៍និងគ្រឿងញៀននិងមន្ត្រីទទួលបន្ទុកសុខភាពសិក្សា(២១-២៣/១២/២០១០) នៅសណ្ឋាគារImperial Garden រាជធានីភ្នំពេញ ដែលរៀបចំដោយក្រសួងអប់រំយុវជននិងកីឡា ក្រោមការឧបត្ថម្ភពីអង្គការ UNFPA ។

-បានចាត់មន្ត្រីជំនាញចូលរួមសិក្ខាសាលា ស្តីពីការឆ្លើយតបមេរោគអេដស៍ដែគូសហគមន៍ដើម្បីប្រជាជនប្រឈម មុខខ្ពស់ដែលធ្វើនៅខេត្តបាត់ដំបង(០៨/១២/២០១០) ខេត្តបន្ទាយមានជ័យ(០៩/១២/២០១០)និងខេត្តសៀម រាប (២០/១២/២០១០) តាមការអញ្ជើញរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ។

-បានចាត់មន្ត្រីជំនាញចូលរួមប្រជុំពិភាក្សា(១៣/១២/២០១០)និងសិក្ខាសាលា(១៧/១២/២០១០) លើប្រធាន បទស្តីពី "សារៈសំខាន់នៃគោលនយោបាយគ្រឿងស្រវឹង" តាមការអញ្ជើញរបស់មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បី អភិវឌ្ឍន៍ និងសន្តិភាព ដើម្បីស្វែងរកអនុសាសន៍ក្នុងការជំរុញឱ្យមានគោល នយោបាយគ្រឿងស្រវឹងនៅកម្ពុជា" ។

ក្នុងនយ័ រួមចំណែកក្នុងយន្តការកាត់បន្ថយគ្រោះថ្នាក់ ជាមួយបណ្តាប្រទេសនៅក្នុង អនុតំបន់ តំបន់ និង អន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានទៅចូលរួមនៅក្នុង :

-សិក្ខាសាលាស្តីពីការអនុវត្តន៍ច្បាប់និងការកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងគ្រឿងញៀន នៅទីក្រុងហាណូយ ប្រទេសវៀតណាម(០២-០៣/១២/២០១០) ។ សិក្ខាសាលានេះ ជាផ្នែកសកម្មភាពមួយនៃការសិក្សាស្រាវជ្រាវរបស់ វិទ្យាស្ថាន**ណូសាល់**(NOSSAL)សំរាប់សុខភាពសកលនៃប្រទេសអូស្ត្រាលី ស្តីពីការអនុវត្តច្បាប់និងការកាត់បន្ថយគ្រោះថ្នាក់ ដែលពាក់ព័ន្ធនឹងការប្រើបំពានគ្រឿងញៀនដែលមានគោលបំណង បង្ហាញមន្ត្រីអនុវត្តច្បាប់ឱ្យយល់ដឹងពីកម្មវិធីកាត់បន្ថយ គ្រោះថ្នាក់ ព្រមទាំងសារប្រយោជន៍និងសារៈសំខាន់នៃកម្មវិធី, ការធ្វើឱ្យមន្ត្រីអនុវត្តច្បាប់យល់ដឹងពីតួនាទីភារកិច្ចរបស់ខ្លួន ក្នុងការចូលរួមអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់,ការយល់ដឹងពីការផ្សារភ្ជាប់ការកាត់បន្ថយគ្រោះថ្នាក់ទៅក្នុងគោលនយោ បាយនៃការប្រើគ្រឿងញៀនខុសច្បាប់ ព្រមទាំងយកចិត្តទុកដាក់ហើយប្រុងប្រយត្ន័ក្នុងការអនុវត្តន៍តួនាទីរបស់នគរបាល ។

-ទស្សនកិច្ចសិក្សាកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ នៅទីក្រុង**មែលប៊ន**(Melborne)ប្រទេសអូស្ត្រាលី ថ្ងៃទី២៥-២៩ ខែវិច្ឆិកាឆ្នាំ២០១០ ។

## *៤.ការពង្រឹងសមត្ថភាពលើការងារអនុវត្តច្បាប់*

ដើម្បីជំរុញនិងលើកទឹកចិត្តដល់មន្ត្រីអនុវត្តច្បាប់ តបតាមការស្នើសុំរបស់ខេត្តបន្ទាយមានជ័យ អគ្គលេខាធិការដ្ឋាន អជបគញ បានផ្តល់លិខិតបញ្ជាក់ការសិក្សា ដល់មន្ត្រីអនុវត្តច្បាប់របស់ខេត្តបន្ទាយមានជ័យចំនួន ៤៧០ នាក់ ដែលបានបញ្ចប់ វគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន កាលពីថ្ងៃទី០១-០៣/១២/២០១០ ។

ដោយឡែក ជាមួយបណ្តាប្រទេសក្នុងតំបន់ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនបានទៅចូលរួមនៅក្នុង :

-សិក្ខាសាលាស្តីពីការបំផ្លាញគ្រឿងញៀន និងសារធាតុគីមីផ្សំ នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី កាលពីថ្ងៃទី ០៨-១០/១២/២០១០ ។

-កិច្ចប្រជុំស្តីពីការទប់ស្កាត់ការបង្វែរសារធាតុគីមីផ្សំគ្រឿងញៀន នៅទីក្រុង**ភើធ**(Perth) ប្រទេសអូស្ត្រាលី ថ្ងៃទី ៣០ខែវិច្ឆិកា ដល់ ថ្ងៃទី០៣ខែធ្នូឆ្នាំ២០១០ ។

-កិច្ចប្រជុំលើកទី៣៤ រវាងថ្នាក់ដឹកនាំនៃភ្នាក់ងារអនុវត្តច្បាប់គ្រឿងញៀនថ្នាក់ជាតិនៅតំបន់អាស៊ី និង ប៉ាស៊ីហ្វិក (HONLEA) ថ្ងៃទី៣០វិច្ឆិកា-០៣ធ្នូ២០១០ នៅទីក្រុងបាងកក ប្រទេសថៃ ។

### ៥-កិច្ចសហប្រតិបត្តិការអន្តរជាតិ :

ដើម្បីចូលរួមអនុវត្តយន្តការត្រួតពិនិត្យគ្រឿងញៀនទ្វេភាគី ត្រីភាគី ពហុភាគី ជាមួយបណ្តាប្រទេសនៅក្នុងអនុតំបន់ តំបន់ និង អន្តរជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានចាត់បញ្ជូនមន្ត្រីជំនាញទៅចូលរួមនៅក្នុងសិក្ខាសាលា វគ្គបណ្តុះបណ្តាល កិច្ចប្រជុំ ទស្សនកិច្ច នានា សរុបបានចំនួន ៧ លើក ក្រោមប្រធានបទស្តីពី :

-ការអនុវត្តន៍ច្បាប់ និងការកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងគ្រឿងញៀន (ទីក្រុងហាណូយ ប្រទេសវៀតណាម ០២-០៣/១២/២០១០) ។

-មជ្ឈមណ្ឌលព្យាបាលអ្នកញៀនគ្រឿងញៀនដោយបង្ខំនៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក (ក្រុងបាងកក ប្រទេសថៃ ១៤-១៦/១២/២០១០) ។

-ដៃគូអនុវត្តកម្មវិធី IOGT-NTO MOVEMENT (ទីក្រុងឆាអាម ប្រទេសថៃ ២៤-២៥/១១/២០១០) ។

-កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងគ្រឿងញៀន (នៅទីក្រុងមែលបិន ប្រទេសអូស្ត្រាលី ២៥-២៩/១១/២០១០) ។

-ការបង្វែរសារធាតុគីមីផ្សំគ្រឿងញៀន (ទីក្រុងភើច ប្រទេសអូស្ត្រាលី ៣០/១១-០៣/១២ /២០១០) ។

-ការបំផ្លាញគ្រឿងញៀន និងសារធាតុគីមីផ្សំ (ទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី ០៨-១០/១២/ ២០១០) ។

-កិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន ទ្វេភាគី កម្ពុជា-ថៃ (កោះឆាង ខេត្តត្រាត ប្រទេសថៃ ថ្ងៃទី២០-២៣/១២/២០១០) ។

ដោយឡែកនៅក្នុងប្រទេស នាថ្ងៃទី០៧-១០/១២/២០១០ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំ ត្រីភាគី / ទ្វេភាគី កម្ពុជា-ឡាវ-វៀតណាម លើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ។ តាមរបៀបវារៈដែលបានគ្រោងទុក រួមមាន កិច្ចប្រជុំត្រីភាគី កម្ពុជា-ឡាវ-វៀតណាម, កិច្ចទ្វេភាគីកម្ពុជា-ឡាវ, កិច្ចប្រជុំទ្វេភាគីកម្ពុជា-វៀតណាម និង កិច្ចប្រជុំទ្វេភាគីវៀតណាម-ឡាវ ។ នៅក្នុងកិច្ចប្រជុំនេះ កម្ពុជាបានចុះហត្ថលេខាលើកំណត់ហេតុចំនួនពីរគឺ :

១-កំណត់ហេតុនៃកិច្ចប្រជុំលើកទី៩ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីផ្សំ រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៃព្រះរាជាណាចក្រកម្ពុជា និង គណៈកម្មាធិការជាតិត្រួតពិនិត្យគ្រឿងញៀននៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ។

២-កំណត់ហេតុនៃកិច្ចប្រជុំលើកទី១០ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន, សារធាតុប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ និងសារធាតុគីមីផ្សំ រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៃព្រះរាជាណាចក្រកម្ពុជា និង គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ជំងឺអេដស៍ និងពេស្យាចារនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ។

### -ការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន :

ដើម្បីអនុវត្តបានសម្រេចនូវយុទ្ធសាស្ត្រទាំង៥ខាងលើ នៅក្នុងខែធ្នូនេះ មន្ទីរប្រឆាំងគ្រឿងញៀន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានធ្វើការប្រមូលសរុបទិន្នន័យប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ហើយទិន្នន័យនេះ ត្រូវបានមជ្ឈ-

មណ្ឌលព័ត៌មានគ្រឿងញៀន នៃអគ្គលេខាធិការដ្ឋាន អជបគញ កំពុងចងក្រងក្នុងប្រព័ន្ធកុំព្យូទ័រ ។ ជាមួយនេះដែរ ដើម្បីជំរុញការងារនេះ អាជ្ញាធរជាតិបានបង្កើតក្រុមបច្ចេកទេសចងក្រងទិន្នន័យព័ត៌មានគ្រឿងញៀន និងបានធ្វើការប្រជុំរៀបចំយន្តការបង្កើត "សាលារៀនបៃតងគំរូគ្មានគ្រឿងញៀន" ។

## III. ការសន្និដ្ឋាន និង វាយតម្លៃ

ខែធ្នូនេះ ក្រុមឈ្មួញគ្រឿងញៀននៃប្រទេសជិតខាងនៅតែបន្តប្រើប្រាស់នូវកលល្បិចជាច្រើន ដើម្បីនាំគ្រឿងញៀនចូលមកកម្ពុជា ជាពិសេស ការប្រើប្រាស់រូបភាពទំនាក់ទំនងជាប្រពៃណីរបស់ប្រជាជន ។ បញ្ហានេះ ទាមទារឱ្យអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន ត្រូវតែបង្កើនការប្រុងប្រយ័ត្នឱ្យបានខ្ពស់បំផុតចំពោះកលល្បិចខាងលើ ។

ទន្ទឹមនេះដែរ លើការងារកាត់បន្ថយតម្រូវការគ្រឿងញៀន យើងក៏បានកត់សម្គាល់ឃើញ ក្រសួង-ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន បានចូលរួមធ្វើសកម្មភាពយ៉ាងសកម្មផុលផុស ក្នុងការងារផ្សព្វផ្សាយអប់រំដើម្បីលើកកម្ពស់ការយល់ដឹងពីច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ធ្វើឱ្យការងារផ្សព្វផ្សាយអប់រំមានវឌ្ឍនភាពគួរកត់សំគាល់ ។

ដោយឡែក ការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យ ស្តីពីការបង្កើតមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ហើយក្រសួងយុត្តិធម៌បានបញ្ចប់ការកែសំរួលច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនជាស្ថាពរ ដែលបច្ចុប្បន្នច្បាប់នេះ បាននិងកំពុងបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី ។

## IV. ទិសដៅការងារត្រួតពិនិត្យគ្រឿងញៀន ខែ មករា ឆ្នាំ២០១១

សេចក្តីដូចបានធ្វើការសន្និដ្ឋាននិងវាយតម្លៃអំពីសភាពការណ៍គ្រឿងញៀន និងចំណុចប្រឈម ក្នុងការអនុវត្តន៍យុទ្ធសាស្ត្រខាងលើនេះ អាជ្ញាធរជាតិបានដាក់ចេញនូវទិសដៅដើម្បីអនុវត្តបន្តដូចតទៅ :

### *១-ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

-បន្តកិច្ចសហការជាមួយក្រសួងជាសមាជិក គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ក្នុងការផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយវិទ្យុ-ទូរទស្សន៍រដ្ឋនិងឯកជន ជាពិសេស តាមកម្មវិធីប្រចាំខែដែលផ្តល់ដោយស្ថានីយទូរទស្សន៍ CTN ។

-បន្តកិច្ចសម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការសរសេរ**សារ**អប់រំពីគ្រឿងញៀន ដាក់នៅលើផលិតរបស់ផលិតកម្មក្នុងស្រុកនានា ។

-បំផុសលើកទឹកចិត្តឱ្យមានការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ និងវិស័យឯកជន ក្នុងការចូលរួមផ្សព្វផ្សាយលើកកំពស់ការយល់ដឹងពីគ្រឿងញៀន ។

-បន្តកិច្ចសម្របសម្រួលជាមួយក្រសួងអប់រំយុវជននិងកីឡា និងអាជ្ញាធរមានសមត្ថកិច្ចរាជធានីភ្នំពេញ ខេត្តបាត់-ដំបង បន្ទាយមានជ័យ សៀមរាប ដើម្បីសមាគមយុវជនខ្មែរ ចុះអនុវត្តកម្មវិធីអប់រំបង្ការការប្រើបំពានគ្រឿងញៀននៅតាមសាលារៀន និងភូមិ ឃុំ សង្កាត់នៃខេត្ត-ក្រុង ដែលជាគោលដៅចាស់របស់សមាគម ។

## ២.ការព្យាបាល ស្តារនីតិសម្បទា និង សមាហរណកម្ម និងការកាត់បន្ថយគ្រោះថ្នាក់នានា

-បន្តជំរុញការសាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅខេត្តព្រះសីហនុ ។

-បន្តកិច្ចសហការជាមួយគំរោង**Treatnet II** របស់អង្គការ**UNODC** ដើម្បីធ្វើការបណ្តុះបណ្តាលចំណេះដឹងជាមូលដ្ឋាន ក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀនដោយផ្អែកលើសហគមន៍ ដល់គ្រូពេទ្យដែលបំរើការងារនៅតាមមន្ទីរពេទ្យបង្អែក និង មណ្ឌលសុខភាព របស់រាជធានីភ្នំពេញ ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង ខេត្តសៀមរាប និងខេត្តព្រះសីហនុ ។

## ៣.ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

-សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត ដើម្បីជំរុញឱ្យអាជ្ញាធរមូលដ្ឋានបន្តយកចិត្តទុកដាក់ធ្វើកិច្ចសន្យារដ្ឋបាលឱ្យបានហ្មឹងម៉ាត់ជាមួយម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ ក្លឹបកំសាន្ត និងកន្លែងសប្បាយនានា នៅមូលដ្ឋានរបស់ខ្លួន ។

-បន្តការស្រាវជ្រាវស៊ើបអង្កេតករណីនាំចូលឱសថព្យាបាលជម្ងឺផ្តាសាយម៉ាក Col Col Co ដែលមានផ្ទុកសារធាតុ Pseudo-Ephedrine(KTC2280) ចំនួន ១២.៨៧៤.000 គ្រាប់ កាលពីថ្ងៃទី២២/៨/២០១០ ។

## ៤.ពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

-បន្តបើកវគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តច្បាប់ នៅខេត្តពោធិសាត់ ខេត្តកំពង់ចាម ខេត្តស្ទឹងត្រែង ក្រោមការគាំទ្រថវិកាដោយទីភ្នាក់ងារអូស្ត្រាលីដើម្បីអភិវឌ្ឍន៍អន្តរជាតិ(AusAID) នៅដើមឆ្នាំ២០១១ និង នៅរាជធានីភ្នំពេញ នៅថ្ងៃទី១១-១២ខែមករាឆ្នាំ២០១១ ក្រោមការគាំទ្រថវិកាដោយអង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជម្ងឺអេដស៍(KHANA) ។

-ត្រៀមរៀបចំផែនការ កម្មវិធីបណ្តុះបណ្តាលដល់មន្ត្រីអនុវត្តច្បាប់សំរាប់ឆ្នាំ២០១១ ជាមួយបណ្តាអង្គការជាដៃគូ ។

## ៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ

-ត្រៀមទៅចូលរួមកិច្ចប្រជុំមន្ត្រីទំនាក់ទំនងគម្រោងH15 ស្តីពីភាពជាដៃគូនៃប្រទេសសមាជិកហត្ថលេខីលើអនុស្សារណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន នៅប្រទេសឡាវនាថ្ងៃទី ១៩-២០ ខែមករា ឆ្នាំ២០១១ ។

-ចាត់តាំងមន្ត្រីជាន់ខ្ពស់ចូលរួមក្នុងកិច្ចប្រជុំអន្តរក្រសួង ដើម្បីរៀបចំខ្លឹមសារកិច្ចប្រជុំគណៈកម្មការចម្រុះសហប្រតិបត្តិការទ្វេភាគី កម្ពុជា-ថៃ លើកទី៧ ដែលនឹងប្រព្រឹត្តទៅនាថ្ងៃទី ០៥/០១/២០១១ នៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

## .ការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន

ដើម្បីអនុវត្តបានសំរេចទិសដៅត្រួតពិនិត្យគ្រឿងញៀនខាងលើ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននឹងបន្តជំរុញការអនុវត្តន៍គោលការណ៍ប្រៀបសមរភូមិប្រឆាំងបទល្មើសគ្រឿងញៀន ដែលក្នុងនោះផ្តោតសំខាន់ទៅលើ :

-ការបន្តកិច្ចសហការជាមួយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ រៀបចំប្រព័ន្ធទិន្នន័យព័ត៌មានគ្រឿងញៀនថ្នាក់ជាតិ ។

-ការបន្តអនុវត្តផែនការប្រតិបត្តិគំរូត្រួតពិនិត្យគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ ។

-ការរៀបចំយន្តការបង្កើត "សាលារៀនបៃតងគំរូគ្មានគ្រឿងញៀន" ។

-ការបន្តរៀបចំផែនការសកម្មភាពជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន រយៈពេល៥ឆ្នាំបន្ត (២០១១-២០១៥) ។

-ត្រៀមរៀបចំកិច្ចប្រជុំដកពិសោធន៍ លើការអនុវត្តន៍ផែនការប្រតិបត្តិត្រួតពិនិត្យគ្រឿងញៀននៅខេត្តបន្ទាយមានជ័យ នាខែមករា ឆ្នាំ២០១១ ។

-ត្រៀមប្រជុំដាក់ផែនការត្រួតពិនិត្យគ្រឿងញៀន នៅតាមបណ្តាខេត្តព្រំដែន កម្ពុជា-ឡាវ ។

-ត្រៀមរៀបចំសន្និបាតប្រចាំឆ្នាំ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**អគ្គលេខាធិការ**

<u>**ចំលងជូន**</u> :

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន

-ឯកឧត្តម កៅ ខុនដារ៉ា អនុប្រធាន អ.ជ.ប.គ.ញ

(ដើម្បីជូនជ្រាប)

-ក្រសួងសមាជិក អ.ជ.ប.គ.ញ

-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត

-នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី

(ដើម្បីមុខការ)

-ឯកសារ-កាលប្បវត្តិ

# រាជធានី-ខេត្ត អង្គភាព ឬ អង្គការ ដែលបានធ្វើការងារផ្សព្វផ្សាយអប់រំ ក្នុងខែ ធ្នូ ឆ្នាំ២០១០

| អង្គភាព | ខ្លឹមសារផ្សព្វផ្សាយ គោលដៅផ្សព្វផ្សាយ និង សមាសភាពចូលរួម | ចំនួនសរុប |
|---|---|---|
| អគ្គលេខាធិការដ្ឋាន អជបគញ | -ការចូលរួមបន្តកិច្ចប្រជុំពិភាក្សាលើប្រធានបទស្តីពី សារៈសំខាន់នៃគោលនយោបាយគ្រឿងញៀនស្រវឹង (១៣-១២-២០១០) និង សិក្ខាសាលាថ្នាក់ជាតិ ស្តីពីសារៈសំខាន់នៃគោលនយោបាយគ្រឿងញៀនស្រវឹង (១៧-១២-២០១០) ១០០ នាក់<br>-ការចូលរួមធ្វើបទបង្ហាញស្តីពីផលប៉ះពាល់នៃគ្រឿងញៀនដល់និស្សិតវិទ្យាស្ថានប៉ៃលិធី សាខាស្ទឹងមានជ័យ(១៦/១២/២០១០) សរុប ១៤០ នាក់<br>-ផ្តល់លិខិតបញ្ជាក់ការសិក្សា ដល់មន្ត្រីនគរបាលខេត្តបន្ទាយមានជ័យដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលស្តីពីការពង្រឹងសមត្ថភាព អនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន (០១-០៣/១២/២០១០) សរុបចំនួន ៤៧០ នាក់ | ៧១០ នាក់ |
| -ស្នងការដ្ឋាន ន.ប ខេត្តរតនគិរី ក្រុងបានលុង ស្រុកកូនមុំ វ៉ើនសៃ អូរយ៉ាដាវ | -ផ្សព្វផ្សាយអប់រំពីផលប៉ះពាល់នៃគ្រឿងញៀន ដល់គ្រូ សិស្សានុសិស្ស នៅក្រុងបានលុង ៨២៣ នាក់ ស្រុកកូនមុំ ១៤០ នាក់ ស្រុកវ៉ើនសៃ ៥០០ នាក់ ស្រុកអូរយ៉ាដាវ ៥២៧ នាក់ | ១.៩៩០ នាក់ |
| -នគរបាលខេត្តព្រះវិហារ ស្រុករវៀង ស្រុកគូលែន ស្រុកត្បែងមានជ័យ ក្រុងព្រះវិហារ | -ផ្សព្វផ្សាយ ច្បាប់ និង គ្រោះថ្នាក់នៃគ្រឿងញៀន ដល់ក្រុមប្រឹក្សាស្រុក ឃុំ មេប៉ុស្តិ៍ មេភូមិ ស្រុករវៀង+ស្រុកគូលែន ៣.០៥៨ នាក់, ស្រុកត្បែងមានជ័យ ៥៧០ នាក់ ក្រុងព្រះវិហា ៣៥ នាក់ | ៣.៦៦៣ នាក់ |
| -នគរបាលខេត្តកែប | -គ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាការពារ ប្រជាពលរដ្ឋ ២២ នាក់, | ២២ នាក់ |
| -នគរបាលខេត្តសៀមរាប | -ផ្សព្វផ្សាយច្បាប់ និង គ្រោះថ្នាក់នៃគ្រឿងញៀន ដល់មន្ត្រីសាលាស្រុក មេឃុំ មេភូមិ នគរបាលប៉ុស្តិ៍ ប្រជាពលរដ្ឋ ក្នុងស្រុកអង្គរធំ ៦៥ នាក់ | ៦៥ នាក់ |
| -នគរបាល ខេត្តកំពង់ចាម | -កម្មវិធីវេទិកាសាធារណៈ(សំណួរ-ចម្លើយ) ដល់មន្ត្រីរាជការភូមិ ឃុំ ស្រុក ប្រជាពលរដ្ឋ ១៦៥ នាក់, | ១៦៥ នាក់ |
| -នគរបាលខេត្តកំពង់ធំ ស្រុកសន្ទុក ប្រាសាទសំបូរ មន្ទីរការងារបណ្តុះ.. | -ផ្សព្វផ្សាយច្បាប់ និង គ្រោះថ្នាក់នៃគ្រឿងញៀន ដល់ប្រជាពលរដ្ឋ ស្រុកសន្ទុក ១០០ នាក់ ប្រាសាទសំបូរ ៦២៦ នាក់ ប្រាសាទបល្ល័ង្ក ៦៥០ នាក់ ស្រុកស្ទោង ១៧៥ នាក់ ស្រុកស្ទឹងសែន ៥៣ នាក់ ទូទាំងខេត្ត ១.១២៥ នាក់ សន្ទុក+កំពង់ស្វាយ ៤៣០ នាក់<br>-ចែកបម្រាមស្តីពីគ្រឿងញៀន ៤៨១ សន្លឹក | ៣.១៦៣ នាក់ |
| -នគរបាលខេត្តកណ្តាល, ស្រុកកោះធំ | -ផ្សព្វផ្សាយច្បាប់ត្រួតពិនិត្យគ្រឿងញៀន ច្បាប់ចរាចរណ៍ ដល់សិស្សវិទ្យាល័យ ហ៊ុន សែន កោះធំ ប្រជាពលរដ្ឋ សមត្ថកិច្ចមូលដ្ឋាន ៣.៩៦៤ នាក់, ស្រុកក្បៀនស្វាយ ៥៥៨ នាក់, | ៤.៥២២ នាក់ |
| -នគរបាលខេត្តតាកែវ, អង្គការ TC | -ផ្សព្វផ្សាយច្បាប់ និង ផលប៉ះពាល់នៃគ្រឿងញៀន ដល់នគរបាល ប្រជាពលរដ្ឋ ក្រុងដូនកែវ ៣១ នាក់ | ៣១ នាក់ |
| -នគរបាលខេត្តបាត់ដំបង ស្រុកកំរៀង ស្រុកបវេល ស្រុកបាណន់ ក្រុងបាត់ដំបង ស្រុកថ្មគោល, សមាគមនារី ស្រុកបវេល, អង្គការកុមារនៃក្តីសង្ឃឹម, | -ផ្សព្វផ្សាយផលប៉ះពាល់នៃគ្រឿងញៀន និងការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ ដល់ប្រជាពលរដ្ឋ និង សិស្សានុសិស្ស នៅស្រុកកំរៀង ៤៥ នាក់, ស្រុកបវេល ៩៥៨ នាក់, ស្រុកបាណន់ ៥១៧ នាក់, ក្រុងបាត់ដំបង ២១៨ នាក់, ស្រុកថ្មគោល ៤.២៤២ នាក់, ស្រុកសំឡូត ១៥២ នាក់, | ៦.១៣២ នាក់ |
| -លេខាធិការដ្ឋាន គ.ញ ប៉ៃលិន សមាគមនារីដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ | -ផ្សព្វផ្សាយពីគ្រោះថ្នាក់នៃគ្រឿងញៀន ការឆ្លងរាលដាលមេរោគអេដស៍/ជម្ងឺអេដស៍ ដល់នារីបំរើការនៅតាមសេវាកំសាន្ត ៨១៧ នាក់, | ៨១៧ នាក់ |
| -នគរបាលខេត្តឧត្តរមានជ័យ ស្រុកត្បែងមានជ័យ ស្រុកបន្ទាយអំពិល | -ផ្សព្វផ្សាយគ្រោះថ្នាក់នៃគ្រឿងញៀន ស្រុកត្បែងមានជ័យ ៤១០ នាក់, ស្រុកបន្ទាយអំពិល ៤៨ នាក់, | ៤៥៨ នាក់ |
| -ន.ប. ខេត្តកំពង់ឆ្នាំង ស្រុកបរិបូណ៌ | -ច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់សិក្ខាកាម នៅស្រុកបរិបូណ៌ ២០ នាក់ | ២០ នាក់ |
| -ន.ប. ខេត្តកំពង់ស្ពឺ ស្រុកបសេដ្ឋ ថ្ពង ភ្នំស្រួច សំរោងទង | -ច្បាប់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ដល់អាជ្ញាធរភូមិ-ឃុំ ប្រជាពលរដ្ឋ ៣.១០៨ នាក់ | ៣.១០៨ នាក់ |
| -ស្នងការដ្ឋាន ន.ប ខេត្តស្វាយរៀង ក្រុងបាវិត ស្រុករមាសហែក | -ការយល់ដឹងពីគ្រឿងញៀន និង ភូមិ ឃុំមានសុវត្ថិភាព នៅក្រុងស្វាយរៀង ២៥៧ នាក់ ក្រុងបាវិត ២៦៥ នាក់ ស្រុករមាសហែក ៧០៦ នាក់ | ១.២២៨ នាក់ |
| -ន.ប. ព្រៃវែង ស្រុកកំពង់លាវ + អង្គការ CCAFFVA | -បញ្ហាអេដស៍ និងគ្រឿងញៀន ដល់អាជ្ញាធរភូមិ-ឃុំស្រុកកំពង់លាវ ៤៧ នាក់ | ៤៧ នាក់ |
| | សរុប | ២៦.១៤១ នាក់ |

## អង្គភាពប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ខែ ធ្នូ ឆ្នាំ២០១០

| ល.រ | អង្គភាពបង្ក្រាប | សរុបរួម | | | ផលិត ចរាចរ ជួញដូរចែកចាយ | | | ប្រើប្រាស់គ្រឿងញៀន | | | ចាប់តាមដីកា | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី | ករណី | សរុប | ស្រី |
| ១ | មន្ទីរប្រឆាំងគ្រឿងញៀន | **៦** | **១៥** | **៣** | ៦ | ១៤ | ៣ | | | | ០ | ១ | ០ |
| ២ | ន.ដ្ឋាន ប្រឆាំងភេរវកម្ម | **១** | **២** | **២** | ១ | ២ | ២ | | | | | | |
| ៣ | នគរបាល ភ្នំពេញ | **៦** | **៧** | **៣** | ៦ | ៧ | ៣ | | | | | | |
| ៤ | នគរបាល ខេត្តកណ្តាល | **១** | **០** | **០** | ១ | ០ | ០ | | | | | | |
| ៥ | នគរបាល ខេត្តកំពង់ឆ្នាំង | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៦ | នគរបាល ខេត្តកំពង់ចាម | **៣** | **៦** | **០** | ៣ | ៦ | ០ | | | | | | |
| ៧ | នគរបាល ខេត្តស្ទឹងត្រែង | **១** | **១** | **០** | ១ | ១ | ០ | | | | | | |
| ៨ | នគរបាល ខេត្តរតនគិរី | **១** | **២** | **១** | ១ | ២ | ១ | | | | | | |
| ៩ | នគរបាល ខេត្តបាត់ដំបង | **២** | **៣** | **០** | ២ | ៣ | ០ | | | | | | |
| ១០ | នគរបាល ខេត្តកោះកុង | **១** | **២** | **១** | ១ | ២ | ១ | | | | | | |
| ១១ | នគរបាល ខេត្តបន្ទាយ/ជ័យ | **៣** | **៣** | **១** | ៣ | ៣ | ១ | | | | | | |
| ១២ | នគរបាល ខេត្តពោធិសាត់ | **១** | **០** | **០** | ១ | ០ | ០ | | | | | | |
| ១៣ | នគរបាល ខេត្តកំពង់ធំ | **១** | **០** | **០** | ១ | ០ | ០ | | | | | | |
| ១៤ | នគរបាល ខេត្តក្រចេះ | **២** | **៤** | **១** | ២ | ៤ | ១ | | | | | | |
| **សរុប** | | **៣០** | **៤៦** | **១២** | **៣០** | ៤៥ | ១២ | | | | **០** | ១ | ០ |

**កំណត់ចំណាំ** ១) ខែធ្នូនេះ ករណីរបស់ខេត្តពោធិសាត់ អគ្គលេខាធិការដ្ឋាន អជបគញ ពុំបានបញ្ចូលនូវវត្ថុតាងប្រេងម្រះព្រៅភ្នំទេ ព្រោះបានបញ្ចូលទៅក្នុងរបាយការណ៍ខែវិច្ឆិការួចហើយ ។

២) ចំនួនបទល្មើសក្នុងរបាយការណ៍របស់មន្ទីរប្រឆាំងគ្រឿងញៀនមានតែ ២៩ ករណីប៉ុណ្ណោះ ប៉ុន្តែរបាយការណ៍របស់អគ្គលេខាធិការដ្ឋាន អជបគញ បន្ថែម១ករណីនាំចូលឱសថមានផ្ទុកសារធាតុផ្សីដូ-អេហ្វេឌ្រីន ១ករណីទៀត សរុបមាន ៣០ ករណី ជនល្មើស សរុប ៤៦ នាក់ ( ស្រី១២នាក់ ។

## សារធាតុគីមីផ្សំ មានច្បាប់អនុញ្ញាតឱ្យនាំចូល ប្រចាំខែ ធ្នូ ឆ្នាំ២០១០

| ឈ្មោះសារធាតុគីមី | ផ្តល់អាជ្ញាបណ្ណ័ដោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | | | ផ្តល់អាជ្ញាបណ្ណ័ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | | សរុប | | |
|---|---|---|---|---|---|---|---|---|---|
| | Kg | L | Amp | Kg | L | Amp | Kg | L | Amp |
| Acid Hydrochloric 37% | | 20 | | | | | | 20 | |
| Acid Hydrochloric 33% | 127.142 | | | | | | 127.142 | | |
| Acid Hydrochloric 32% | 100.000 | | | | | | 100.000 | | |
| Caustic Soda 90% | 100.000 | | | | | | 100.000 | | |
| Acid Sulfuric | 1.300.000 | 5 | | | | | 1.300.000 | 5 | |
| Ethyl Acetate | | 5 | | 3.000 | | | 3.000 | 5 | |
| Caustic Soda Flake | 140.000 | | | | | | 140.000 | | |
| Aceton | | 10 | | 21.500 | | | 21.500 | 10 | |
| Solvent P/W | | 54 | | | | | | 54 | |
| Soda Ash | 100.000 | | | 450.000 | | | 550.000 | | |
| Acid Acetic | 50.000 | | | 38.000 | | | 88.000 | | |
| Methylene Chloride | 4.000 | | | 52.000 | | | 56.000 | | |
| Caustic Soda | | | | 200.000 | | | 200.000 | | |
| Glacial Acetic Acide | | | | 50.000 | | | 50.000 | | |
| Sodium Hypochloride | | | | 3.000 | | | 3.000 | | |
| Methyl Ethyl Ketone | | | | 130.000 | | | 130.000 | | |
| Toluene | | | | 155.000 | | | 155.000 | | |
| Sulfuric Acid | | | | 1.000 | | | 1.000 | | |
| Solvent | | | | 35.000 | | | 35.000 | | |
| TOTAL | 1.921.142 | 94 | | 1.138.500 | | | 3.059.642 | 94 | |